# សុន្ទរកថារបស់ លោក ហ្វូជីម៉ុតូ តូស៊ីគី
# លេខាទី២ ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ
# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការ
# នៅសហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង ក្នុងខេត្តស្វាយរៀង

ថ្ងៃទី ៣០ ខែសីហា ២០១៦

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព **ឯកឧត្តម ម៉ម អំណាត់** រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សូមគោរព **លោកជំទាវ ពៅ សុនាព** អភិបាលរងនៃគណៈអភិបាលខេត្តស្វាយរៀង
- សូមគោរព **លោកស្រី ម៉ាត់ស៊ូអ៊ូរ៉ា អាយុមី** នាយិកាអង្គការអាយ.វី.វ៉ាយ
- សូមគោរព អស់លោក លោកស្រីទាំងអស់ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានមកចូលរួមក្នុងពិធីសម្ពោធនៅសហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង(SAC) ក្នុងខេត្តស្វាយរៀងនេះ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ម អំណាត់** រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង**លោកជំទាវ ពៅ សុនាព** អភិបាលរងនៃគណៈអភិបាលខេត្តស្វាយរៀង ដើម្បីប្រារព្ធពិធីសម្ពោធមជ្ឈមណ្ឌលប្រមូលផ្តុំកសិផលថ្មីមួយ។

មជ្ឈមណ្ឌលប្រមូលផ្តុំកសិផលថ្មីមួយនេះ ត្រូវបានសាងសង់ឡើងដោយអង្គការអាយ.វី.វ៉ាយ ក្រោមជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។ តាមរយៈគ្រោងការណ៍នៃជំនួយនេះ រដ្ឋាភិបាលជប៉ុន អាចផ្តល់ការគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនប្រកបដោយប្រសិទ្ធភាព។ រដ្ឋាភិបាលជប៉ុន ក៏បានរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជាលើវិស័យជាច្រើននៅក្នុងខេត្តមួយចំនួន ដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាលជប៉ុន។

អង្គការអាយ វី វ៉ាយ បានបន្តសកម្មភាពរបស់ខ្លួននៅក្នុងខេត្តស្វាយរៀងអស់រយៈពេល១៧ឆ្នាំមកហើយ។ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០១៣ ដល់ ខែមិនា ឆ្នាំ២០១៦ អង្គការ អាយ.វី.វ៉ាយ បានអនុវត្តនូវ "គម្រោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទតាមរយៈការបង្កើតនូវការគ្រប់គ្រងដែលមាននិរន្តរភាពក្នុងសហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង(SAC)" ក្រោមជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។ គម្រោងនេះ មានគោលបំណងបង្កើនផលិតផល និងការផ្គត់ផ្គង់បន្លែរបស់សហគមន៍SAC ដោយបង្កើតនូវបណ្តាញផ្គត់ផ្គង់មួយ និងពង្រឹងបន្ថែមទៀតនូវការគ្រប់គ្រងសហគមន៍អោយកាន់តែប្រសើរ តាមរយៈការបណ្តុះបណ្តាលកសាងសមត្ថភាព ដើម្បីធ្វើអោយសហគមន៍SAC មាននិរន្តរភាព និងឯករាជ្យភាពនាពេលអនាគត។

ដោយមានការជ្រោមជ្រែងពីអង្គការអាយ.វី.វ៉ាយ និងប្រជាកសិករ បច្ចុប្បន្នសហគមន៍ SAC អាចផ្គត់ផ្គង់បន្លែជាច្រើននៅតាមផ្សារទំនើបនានានៅរាជធានីភ្នំពេញ ដូចជាផ្សារទំនើបAEONជប៉ុនជាដើម។ អង្គការអាយ.វី.វ៉ាយ បានរួមចំណែកមិនត្រឹមតែផ្គត់ផ្គង់បន្លែជាច្រើនសម្រាប់អតិថិជននៅកម្ពុជាប៉ុណ្ណោះទេ ថែមទាំងជួយលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាកសិករផងដែរ។

ដោយមើលឃើញគម្រោងដែលត្រូវបានអនុវត្តដោយអង្គការអាយ.វី.វ៉ាយអស់រយៈពេលបីឆ្នាំកន្លងមកនេះ រដ្ឋាភិបាលជប៉ុន បានសម្រេចចិត្តគាំទ្រនូវគម្រោងថ្មីរបស់អង្គការអាយ.វី.វ៉ាយជាបន្តទៀតនៅក្នុងខេត្តព្រះវិហារ និងខេត្តស្វាយរៀងរួមមាន៖ ការសាងសង់មជ្ឈមណ្ឌលប្រមូលផ្តុំកសិផលថ្មីមួយ ដើម្បីរួមចំណែកក្នុងការដាំបន្លែ ប្រមូលផ្តុំបន្លែ វេចខ្ចប់បន្លែ និងចែកចាយ

បន្ថែប្រកបដោយប្រសិទ្ធិភាពខ្ពស់។

ខ្ញុំមានសេចក្តីរីករាយដែលបានមកឃើញមជ្ឈមណ្ឌលប្រមូលផ្តុំកសិផលថ្មីនេះ។ជំនួយឧបត្ថម្ភឥតសំណងរបស់ជប៉ុនទាំងនេះ គឺអនុលោមតាមគោលនយោបាលរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះរួមមានគោលនយោបាយអភិវឌ្ឍផ្នែកឧស្សាហកម្ម ក្នុងការពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការបូកបន្ថែមនូវតម្លៃផលិផលកសិកម្ម តាមរយៈការលើកស្ទួយផលិតកម្មស្បៀងអាហារជាដើម។ ជាមួយនិងការកែលម្អដំណើរការរបស់មជ្ឈមណ្ឌលប្រមូលផ្តុំកសិផលនេះ ខ្ញុំសង្ឃឹមថាប្រជាកសិករជាច្រើន នឹងអាចរកប្រាក់ចំណូលបានច្រើនជាងមុន និងកែលម្អគុណភាពនៃជីវិតរបស់ពួកគេកាន់តែល្អប្រសើរ។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវការកោតសសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកក្នុងការអនុវត្តនូវគម្រោងនេះអោយបានបញ្ចប់ទៅដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។ ខ្ញុំក៏សង្ឃឹមផងដែរថា មជ្ឈមណ្ឌលប្រមូលផ្តុំកសិផលនេះ នឹងត្រូវបានថែទាំអោយនៅគង់វង្សល្អ ដើម្បីទុកជានិមិត្តរូបដ៏យូរអង្វែងនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**